**វិទ្យាស្ថានសភាកម្ពុជា**
**PARLIAMENTARY INSTITUTE OF CAMBODIA**
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៨ ខែកញ្ញា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺះ

- ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ កំពុងកើនឡើងនៅកម្ពុជា
- ឱនភាពថវិការបស់ហ្វីលីពីនមានការកើនឡើង
- អត្រាការប្រាក់ធនាគារសហព័ន្ធរបស់សហរដ្ឋអាមេរិក បានកើនឡើងដូចការរំពឹងទុក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការចិញ្ចឹមមាន់លក្ខណៈគ្រួសារ កំពុងកើនឡើងនៅកម្ពុជា

យោងតាមអង្គការភីនកម្ពុជា (People in Need Cambodia, PIN) គ្រួសារដែលពឹងផ្អែកលើការចិញ្ចឹមមាន់នៅក្នុងប្រទេសកម្ពុជាមាន<u>ការកើនឡើង</u> ដែលក្នុងនោះមួយផ្នែក គឺដោយសារតែគម្រោងទឹកប្រាក់ចំនួន១,៣៥លានដុល្លាអាមេរិក ដែលឧបត្ថម្ភដោយសហគមន៍អ៊ឺរ៉ុប។ គ្រួសារដែលបានចូលរួមក្នុងគម្រោងនេះ មានចំនួនសរុបច្រើនជាង ១០.០០០គ្រួសារ ហើយចំនួនសត្វមាន់បានកើនឡើងច្រើនជាង៩០% នៅក្នុងរយៈពេលជាង២ឆ្នាំ។

គោលដៅរបស់គម្រោងនេះគឺជួយដល់កសិករលើផ្នែកបច្ចេកទេសក្នុងផលិតកម្មចិញ្ចឹមមាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងជម្រុញការផ្គត់ផ្គង់សាច់ក្នុងស្រុក និងលើកកម្ពស់ចំណូលគ្រួសារកម្ពុជា តាមរយៈដំណើរការ។

យោងតាម លោក អ៊ុក សារិន អគ្គនាយករងនៃនាយកដ្ឋានផលិតកម្ម និងសុខភាពសត្វ បានអោយដឹងថា ទន្ទឹមនឹងការកើនឡើងនូវតម្រូវការសាច់ ឧស្សាហកម្មសាច់មាន់មានការធ្លាក់ចុះដោយសារតែកសិករវ័យក្មេងបានបោះបង់ចោលការចិញ្ចឹមសត្វដើម្បីទៅធ្វើការនៅរោងចក្រកាត់ដេរ ។

### តារាងប្រចាំសប្តាហ៍៖ ចំណូលពន្ធកម្ពុជា ក្នុងត្រីមាសទី១ ឆ្នាំ ២០១៨

តារាងនៅក្នុងសប្តាហ៍នេះបង្ហាញអំពីចំណូលពន្ធកម្ពុជា ក្នុងត្រីមាសទី១ឆ្នាំ២០១៨ បើប្រៀបធៀបកំឡុងពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ដោយបែងចែកជាចំណូលបានមកពីពន្ធផ្ទាល់ ពន្ធប្រយោល និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ។

ចំណូលដែលបានមកពីពន្ធប្រយោល មានការកើនឡើងគួរអោយកត់សម្គាល់ក្នុងឆ្នាំ២០១៨ដែលកើនដល់ទៅ២,៤១២ប៊ីលានរៀល។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ មិនមានការប្រែប្រួលទេ ក្នុងកំឡុងពេលដូចគ្នា។ រីឯការប្រមូលពន្ធផ្ទាល់ក្នុងឆ្នាំ២០១៨ គឺទាបជាង

ឆ្នាំ២០១៦ និង២០១៧។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនទាន់អាចសន្និដ្ឋានបានថា ការអនុវត្តមិនមានប្រសិទ្ធភាព ព្រោះទិន្នន័យនេះមិនទាន់អាចប្រៀបធៀបបានទេ ដោយសារតែទិន្នន័យមួយចំនួនមិនទាន់មានរហូតដល់ផិតចុងឆ្នាំ (ឆ្នាំ២០១៦ និងឆ្នាំ២០១៧ ត្រូវបានគណនាឡើងវិញ ដោយដាក់បញ្ចូលទិន្នន័យចុងក្រោយទាំងអស់នៃឆ្នាំទាំងនោះ)។

### ចំណូលពន្ធកម្ពុជានៅក្នុងត្រីមាសទី១ ឆ្នាំ២០១៨




| | ពន្ធផ្ទាល់ | ពន្ធប្រយោល | ពន្ធលើពាណិជ្ជកម្មអន្តរជាតិ |
|---|---|---|---|
| ២០១៦ | ៨៩៧ | ១៨១៨ | ៥៤០ |
| ២០១៧ | ១២៧៩ | ២១៨០ | ៤៥៦ |
| ២០១៨ | ៧៨២ | ២៤១២ | ៥១៥ |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មផ្សេងទៀត

### ឱនភាពថវិការបស់ហ្វីលីពីនមានការកើនឡើង

បើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ហ្វីលីពីន បានបង្ហាញថា ឱនភាពថវិកាសរុប នៅក្នុងខែសីហានេះ មានចំនួន PHP ២,៦ ប៊ីលាន បើធ្វើការប្រៀបធៀបទៅនឹងឆ្នាំមុន ដែលមានអតិរេកចំនួន PHP ២៨,៨ប៊ីលាន ក្នុងកំឡុងដូចគ្នា។ ទោះបីជាចំណូលមានការកើនឡើង ១១,៥%ក៏ដោយ ក៏ចំណាយរបស់រាជរដ្ឋាភិបាលបានកើនឡើងច្រើនដល់ ២៨,៧%។

ចាប់ពីខែមករាដល់ខែសីហា ឆ្នាំ២០១៨ ឱនភាពថវិកាបានកើនឡើងចំនួន PHP ២៨២ ប៊ីលាន ពី PHP ១៧២,២ ក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០១៧។ សម្រាប់ឆ្នាំ២០១៨ រដ្ឋាភិបាលបានធ្វើការព្យាករណ៍ថា ឱនភាពថវិកានឹងមានចំនួន PHP ៥២៣,៦ប៊ីលាន ដែលស្មើនឹង ៦,៣%នៃផ.ស.ស។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### អត្រាការប្រាក់ធនាគារសហព័ន្ធរបស់សហរដ្ឋអាមេរិក បានកើនឡើងដូចការរំពឹងទុក

នៅក្នុងសប្តាហ៍នេះ គណៈកម្មាធិការទីផ្សារចំហរសហព័ន្ធ (FOMC) បានសម្រេចតម្លើងគម្លាតសម្រាប់អត្រាការប្រាក់សហព័ន្ធ ចំនួន ២៥ពិន្ទុមូលដ្ឋាន(basic points) ក្នុងរវាង ២% ទៅ ២,២៥% (បើយោងតាមសារព័ត៌មានចេញផ្សាយដោយធនាគារសហព័ន្ធ)។ ការផ្លាស់ប្តូរនេះ ដោយសារតែមើលឃើញទៅលើកំណើនដ៏រឹងមាំនៃសេដ្ឋកិច្ច អត្រានិកម្មភាពទាប និងអត្រាអតិផរណាដែលនៅតែស្ថិតនៅក្រោម ២%។

ការបង់អត្រាការប្រាក់ទៅលើសមតុល្យដែលត្រូវបង់ និងទុនបម្រុងដែលលើស ក៏ត្រូវបានកើនឡើងដល់២,៧៥% (កំណើន០,២៥ ពិន្ទុភាគរយ)។

ការផ្លាស់ប្តូរនេះត្រូវបានគេរំពឹងថានឹងធ្វើឲ្យរូបិយវត្ថុដុល្លារមានតម្លៃជាងមុន ហើយដែលនាំឲ្យប្រាក់រៀលមានតម្លៃខ្ពស់ដែរ និងធ្វើអោយការនាំចេញរបស់កម្ពុជាមិនសូវមានការប្រកួតប្រជែង។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាអតិផរណារបស់ប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃ ប្រទេសតៃវ៉ាន់ និងប្រទេសកូរ៉េខាងត្បូង ព្រមទាំងទិន្នន័យតុល្យភាពពាណិជ្ជកម្មនៅក្នុងប្រទេសកូរ៉េខាងត្បូង និងប្រទេសថៃផងដែរ ។

ខាងក្រោមនេះ គឺជាប្រតិទិនពេញលេញដែលបង្ហាញពីទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងធ្វើការបង្ហាញនៅសប្តាហ៍បន្ទាប់៖

ថ្ងៃច័ន្ទ ទី ០១ ខែតុលា

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា

- អត្រាអតិផរណារបស់ប្រទេសថៃ សម្រាប់ខែកញ្ញា
- សន្ទស្សន៍ភាពជឿជាក់ទៅលើពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់ខែកញ្ញា

ថ្ងៃអង្គារ ទី០២ ខែតុលា

- ទិន្នន័យលទ្ធផលការសាងសង់ (construction output) របស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែសីហា
- ផលិតកម្មឧស្សាហកម្មរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែសីហា
- ទិន្នន័យការលក់រាយរបស់ប្រទេសថៃ សម្រាប់ខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសប្រ៊ុយណេ សម្រាប់ខែមិថុនា និងកក្កដា
- កំណើន ផ.ស.ស របស់ប្រទេសប្រ៊ុយណេ សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៨
- ទិន្នន័យការលក់រាយរបស់ហុងកុង សម្រាប់ខែសីហា
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់ របស់ប្រទេសជប៉ុន សម្រាប់ខែកញ្ញា

ថ្ងៃពុធ ទី០៣ ខែតុលា

- សន្ទស្សន៍ការគ្រប់គ្រងសេវាកម្ម NiKei ប្រទេសជប៉ុន សម្រាប់ខែកញ្ញា
- សន្ទស្សន៍ការគ្រប់គ្រង NiKei ប្រទេសសិង្ហបុរី សម្រាប់ខែកញ្ញា
- សន្ទស្សន៍តម្លៃលក់រាយ របស់ប្រទេសហ្វីលីពីន សម្រាប់ខែសីហា

ថ្ងៃព្រហស្បត្តិ៍ ទី ០៤ ខែតុលា

- ទិន្នន័យការទុនបំរុងរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- ទិន្នន័យការវិនិយោគមូលប័ត្របំណុលបរទេសរបស់ប្រទេសជប៉ុន សម្រាប់ថ្ងៃទី២៩ ខែកញ្ញា
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់របស់ប្រទេសថៃ សម្រាប់ខែកញ្ញា
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់របស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា
- សន្ទស្សន៍ការគ្រប់គ្រងសេវាកម្ម NiKei ហុងកុង សម្រាប់ខែកញ្ញា

ថ្ងៃសុក្រ ទី ០៥ ខែកញ្ញា

- អត្រាអតិផរណារបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- ទិន្នន័យការចំណាយរបស់គ្រួសាររបស់ជប៉ុន សម្រាប់ខែសីហា
- អត្រាអតិផរណារបស់ប្រទេសហ្វីលីពីន សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់ប្រទេសតៃវ៉ាន់ សម្រាប់ខែកញ្ញា
- ទិន្នន័យទុនបម្រុងរបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែសីហា